**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦១) |
| ភាគីដាក់ឯកសារ៖ | មេធាវីការពារក្តីរបស់ យឹម ទិត្យ |
| ដាក់ជូន៖ | អង្គបុរេជំនុំជម្រះ |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Nov-2019, 08:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹង ការចេញដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង ០០៤

---

**ដាក់ដោយ÷**

**សហមេធាវី**

សូ មូស្សេវិន្ទី
Suzana TOMANOVIĆ

**ផ្ញើជូន÷**

**ចៅក្រមអង្គបុរេជំនុំជម្រះ÷**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហួត វុទ្ធី

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

ចៅក្រមបម្រុង Steven J. BWANA

០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦១)

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤**

# សេចក្ដីផ្ដើម

១. អនុលោមតាមវិធាន ២១ វិធាន ៦៧(៥) និងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង") លោក **យឹម ទិត្យ** តាមរយៈសហមេធាវីរបស់ខ្លួន ("មេធាវីការពារក្ដី") សូមដាក់*បណ្ដឹងឧទ្ធរណ៍របស់លោក **យឹម ទិត្យ** ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង ០០៤* ("បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ") ដោយស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") បដិសេធដីកាដំណោះស្រាយ*ទាំងពីរ* ដែលមានវិការៈ ដែលបានចេញដាច់ដោយឡែកពីគ្នាដោយសហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ) ហើយ លើសពីនេះទៀត ក៏ស្នើសុំឱ្យ អ.ប.ជ (i) រំលត់ និងបដិសេធរឿងក្ដីប្រឆាំងនឹងលោក **យឹម ទិត្យ** ទាំងស្រុង ឬ (ii) បង្វិលសំណុំរឿងជូនសហចៅក្រមស៊ើបអង្កេតទាំងពីរវិញ ("សហចៅក្រមស៊ើបអង្កេត") ឱ្យចេញដីកាដំណោះស្រាយរួមគ្នាតែមួយ ឬ (iii) វាយតម្លៃសំណុំរឿង ០០៤ និងចេញដីកាដំណោះស្រាយដោយខ្លួនឯងវិញ។

២. នៅពេលជ្រើសរើសចេញដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤ ចំនួនពីរផ្ទុយគ្នា និងដោយឡែកពីគ្នាបែបនេះ ទាំង ស.ច.ស.ជ និង ស.ច.ស.អ បានអនុវត្តផ្ទុយពី*រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* ("រដ្ឋធម្មនុញ្ញ") *ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* ("ច្បាប់ អ.វ.ត.ក") និងវិធានផ្ទៃក្នុង។ ដីកាដំណោះស្រាយ ដែល ស.ច.ស ទាំងពីរបានដាក់ជូន ត្រូវតែទទួលបានការបដិសេធ ដោយសារវិការៈផ្នែកនីតិវិធី អនុលោមតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្ដីសន្និដ្ឋានថា អ.ប.ជ ត្រូវតែធ្វើអន្តរាគមន៍ នាពេលនេះ ដើម្បីបិទបញ្ចប់កិច្ចស៊ើបសួរពិតប្រាកដសម្រាប់ លោក **យឹម ទិត្យ** ស្របទៅតាមសិទ្ធិរបស់លោក និងដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់លោកក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## ប្រវត្តិនីតិវិធី

៣. មេធាវីការពារក្តីសូមយោងទៅប្រវត្តិនីតិវិធី ដែលបានលើកឡើងនៅក្នុង *ចម្លើយតបរួមរបស់* ***យឹម ទិត្យ*** *ទៅនឹងដីកាសន្និដ្ឋានស្ពាតររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ*[1]។

៤. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ស.ច.ស.ជ បានចេញ *ដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ* (ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ) ជាភាសាខ្មែរ[2] និង ស.ច.ស.អ បានចេញ*ដីកាដំណោះស្រាយ* ("ដីកាដំណោះស្រាយរបស់ ស.ច.ស.អ") ជាភាសាអង់គ្លេស[3]។

៥. សំណៅដីកាដំណោះស្រាយរបស់ ស.ច.ស.ជ ដែលបានបកប្រែជាភាសាអង់គ្លេស ត្រូវបានចេញនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៩។ ដោយសារតែ "*ភាពខុសឆ្គងដែលអាចមើលឃើញ*" នៅក្នុងការបកប្រែ សំណៅកំណែថ្មីមួយត្រូវបានជូនដំណឹងនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩[4]។

៦. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ អនុវត្តតាមរយៈពេលនៃការជូនដំណឹងដែល អ.ប.ជ បានយល់ព្រមបង្កើន[5] មេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងនោះ[6]។

---

[1] ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ពាតររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D378/5 កថាខណ្ឌ ១៤-១០៥។

[2] ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381។

[3] ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382។

[4] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំឱ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាបន្ទាន់ឱ្យផ្តល់នូវការបកប្រែដោយត្រឹមត្រូវជាភាសាអង់គ្លេស នូវដីកាសម្រេចលើកលែងចោទប្រកាន់ចំពោះ យឹម ទិត្យ និងផ្អាកកាលបរិច្ឆេទកំណត់នៃបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/12 និងឯកសារ D382/13 កថាខណ្ឌ ៨។ សូមមើលផងដែរ៖ សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/16 និងឯកសារ D382/19 ទំព័រ ៥-៧។

[5] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពន្យារកាលបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D381/3 និង D382/3 ទំព័រ ៣-៥។

[6] ការជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ៖ ការជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាជាតិ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩

៧. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់ *សំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ*[7]។

៨. នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ស.ព.អ បានដាក់ *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមទំព័រ និងពេលវេលាកំណត់ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ* [8]។

៩. នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹង *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមទំព័រ និងពេលវេលាកំណត់ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ* [9]។

១០. នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ អ.ប.ជ បានចេញ *សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤* ដែល អ.ប.ជ បានឯកភាពផ្តល់ជូនរយៈពេល ៤៥ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីកំណែបកប្រែដីកាដំណោះស្រាយរបស់ ស.ច.ស.ជ ជាភាសាអង់គ្លេស ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ និងបានបង្គាប់ឲ្យភាគី ដាក់បណ្តឹងឧទ្ធរណ៍ដោយឡែកៗប្រឆាំងដីកាដំណោះ

---

ឯកសារ D381/7 និងការជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D382/9។

[7] សំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/8 និងឯកសារ D382/10។

[8] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/13 និងឯកសារ D382/16។

[9] ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/15 និងឯកសារ D382/18។

ស្រាយនីមួយៗនៅក្នុងឯកសារផ្សេងៗ[10]។

## ច្បាប់ជាធរមាន

១១. ច្បាប់ជាធរមានបានបង្ហាញនៅក្នុងមូលដ្ឋានបណ្តឹងឧទ្ធរណ៍ដូចខាងក្រោម។

## ភាពអាចទទួលយកបាន

១២. បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន អនុលោមតាមវិធាន ២១ វិធាន ៦៧(៥) និងវិធាន ៧៤ នៃវិធានផ្ទៃក្នុង។

១៣. វិធាន ៦៧(៥) ចែងថា ដីកាដំណោះស្រាយបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ ដូចមានចែងនៅក្នុងវិធាន ៧៤ នៃវិធានផ្ទៃក្នុង។ វិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង ចែងអំពីដីកាបង្គាប់ និងសេចក្តីសម្រេចរបស់ ស.ច.ស ទាំងពីរ ដែលមេធាវីការពារក្តីអាចប្តឹងឧទ្ធរណ៍។ ជាក់លាក់ជាងនេះ វិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យមេធាវីការពារក្តី ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាតម្កល់យុត្តាធិការរបស់ អ.វ.ត.ក។

១៤. វិធាន ២១ នៃវិធានផ្ទៃក្នុងចែងអំពីលក្ខខណ្ឌនៃការជំនុំជម្រះដោយយុត្តិធម៌ ដែល អ.វ.ត.ក មានកាតព្វកិច្ចត្រូវអនុវត្តស្របតាមមាត្រា ១៣(១) នៃ*កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ* ("កិច្ចព្រមព្រៀងរវាង កម្ពុជា និង អ.ស.ប")[11]។ ទោះបីជាវិធាន ២១ នៃវិធានផ្ទៃក្នុង ពុំចែងច្បាស់លាស់អំពីមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ អ.ប.ជ បានសម្រេចថា "អង្គបុរេជំនុំជម្រះមានសមត្ថកិច្ចធ្វើការពិចារណាលើមូលដ្ឋាននានា ដែលបានលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលមិនត្រូវបានរៀបរាប់ច្បាស់លាស់ក្រោមវិធាន ៧៤(៣)

---

[10] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/16 និងឯកសារ D382/19 ទំព័រ ៥-៧។

[11] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ១៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៧។

នៃវិធានផ្ទៃក្នុង" ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ[12]។ ជាពិសេស ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អ.ប.ជ បានសម្រេចថា "នៅពេលដែលបណ្តឹងឧទ្ធរណ៍ដែលបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះតាមវិធាន ៧៤ នៃវិធានផ្ទៃក្នុង លើកឡើងអំពីបញ្ហាដែលមិនអាចឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកែតម្រូវបាន និងមិនអនុញ្ញាតឱ្យមានលទ្ធភាពប្តឹងឧទ្ធរណ៍នៅដំណាក់កាលនេះបាន នឹងបង្កការខូចខាតដែលមិនអាចជួសជុលបានដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ វិធាន ២១ នៃវិធានផ្ទៃក្នុង ធានាការអនុវត្តដើម្បីពង្រីកវិសាលភាពនៃវិធាន ៧៤ នៃវិធានផ្ទៃក្នុង មួយករណីម្តងៗ"[13]។

១៥. ជាក់ស្តែង ដីកាដំណោះស្រាយត្រូវតម្កល់ ឬ បដិសេធយុត្តាធិការនៃ អ.វ.ត.ក លើជនជាប់ចោទនីមួយៗ។ ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា ពុំត្រូវបានប្រមើលមើលទុក ហើយវិធានផ្ទៃក្នុងក៏ពុំអនុញ្ញាតឱ្យធ្វើដូច្នេះដែរ។ ការដែលចេញដីកាដំណោះស្រាយពីរ ដែលមានវិការៈ និងពុំបានឯកភាពគ្នាលើការសម្រេចលើយុត្តាធិការបុគ្គល គឺជាបញ្ហាដែលពាក់ព័ន្ធជាសារវ័ន្តលើករណីថាតើតុលាការមានយុត្តាធិការស្របច្បាប់ ចំពោះ លោក **យឹម ទិត្យ** ដែរឬទេ ហេតុដូច្នេះ មូលដ្ឋាននេះបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង។

១៦. ម្យ៉ាងវិញទៀត ការដែលចេញដីកាដំណោះស្រាយពីរបែបនេះ មានន័យថា ស.ច.ស បានបង្កព្យសនកម្ម មិនអាចជួសជុលបាន ប៉ះពាល់សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដល់ លោក **យឹម ទិត្យ** ហើយបានរំលោភវិធាន ២១ នៃវិធានផ្ទៃក្នុង និងបានបំពានកាតព្វកិច្ចអនុលោមតាមច្បាប់អន្តរជាតិ។ ស.ច.ស៖

- បានធ្វើឱ្យប៉ះពាល់សច្ចធារណ៍និរទោសរបស់ លោក **យឹម ទិត្យ** ដោយខកខានក្នុងការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ* ចំពោះការ

---

[12] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៧១។ សូមមើលផងដែរ៖ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ D427/4/15 កថាខណ្ឌ ១៨។

[13] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៨។

វាយតម្លៃលើអង្គហេតុ[14]។

- បានរំលោភសិទ្ធិរបស់ លោក **យឹម ទិត្យ** ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់[15]។

- បានធ្វើឲ្យភាន់ច្រឡំ ពុំមែនបានបញ្ជាក់បំភ្លឺអំពីមូលដ្ឋាននៃបទចោទនោះឡើយ ដែលជាការរំលោភសិទ្ធិរបស់ លោក **យឹម ទិត្យ** ក្នុងការទទួលបានការជូនដំណឹងភ្លាមៗ និងលម្អិតអំពីលក្ខណៈ និងមូលដ្ឋាននៃបទចោទដាក់បន្ទុកខ្លួន ប្រសិនបើមាន[16] ហើយ

- បានបង្កឲ្យមានកិច្ចដំណើរការនីតិវិធីស្មុគស្មាញមិនចាំបាច់លើបញ្ហាសុពលភាពនៃការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា ដោយសារខកខានក្នុងការចេញដីកាដំណោះស្រាយរួមមួយ ឬ លើកលែងចោលកិច្ចដំណើរការនីតិវិធី ដែលជាហេតុធ្វើឲ្យមានការពន្យារពេលនៃកិច្ចដំណើរការនីតិវិធីបន្ថែម ដែលមិនអាចទទួលយកបានរួចទៅហើយប្រឆាំង លោក **យឹម ទិត្យ** អស់រយៈពេលជាង ១៣ ឆ្នាំ និងរំលោភសិទ្ធិរបស់ លោក **យឹម ទិត្យ** ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[17]។

អាស្រ័យហេតុនេះ មេធាវីការពារក្តីសន្និដ្ឋានថា មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មួយនេះអាចទទួលយកបាន អនុលោមតាម ការធានាជាសារវន្តផ្អែកតាមលក្ខខណ្ឌតម្រូវនៃវិធាន ២១។

១៧. មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍មួយដោយឡែកប្រឆាំងនឹងដីកាដំណោះស្រាយរបស់ ស.ច.ស.អ ដើម្បីលើកឡើងមូលដ្ឋានទាំងអស់នៅក្នុងបណ្តឹងឧទ្ធរណ៍ ដែល តាមផ្លូវច្បាប់ និង

---

[14] សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១, ៣០១៤។ សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ២២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

[15] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(១)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ថ្មី(ក)។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[16] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(ក)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ថ្មី(ក)។ វិធាន ២១(១)(ឃ)

[17] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(គ)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥ថ្មី(គ)។

នីតិវិធី មានលក្ខណៈដាច់ដោយឡែកពីដីកាដំណោះស្រាយរបស់ ស.ច.ស.ជ ទៅតាមសេចក្តីបង្គាប់របស់ អ.ប.ជ[18]។ ដោយមើលឃើញការព្រួយបារម្ភរបស់ អ.ប.ជ ចំពោះប្រសិទ្ធភាពនៃកិច្ចដំណើរការតុលាការ និងនីតិវិធី ជាពិសេស សេចក្តីសន្និដ្ឋាននៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អាចទាមទារឱ្យមានដំណើរការនីតិវិធីដោយឡែក មេធាវីការពារក្តី សូមដាក់ *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរ* ដែលមានមូលដ្ឋានបណ្តឹងឧទ្ធរណ៍តែមួយ គត់ពាក់ព័ន្ធនឹងដីកាដំណោះស្រាយទាំងពីរ[19]។ កំហុសអង្គច្បាប់នៅក្នុង *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទាំងពីរ* កើតឡើងដូចគ្នាតាមរយៈដីកាដំណោះស្រាយទាំងពីរ ហើយបញ្ហានេះលុបការបំបែកកិច្ចដំណើរការនីតិវិធីតាមរយៈការចេញដីកាដំណោះស្រាយទាំងពីរ ហើយតម្រូវឱ្យមានដំណោះស្រាយរួមគ្នា គឺ ការបដិសេធដីកាដំណោះស្រាយដែលមានវិការៈទាំងពីរនេះ។

## បទដ្ឋាននៃការពិនិត្យមើលឡើងវិញ

១៨. អ.ប.ជ យល់ឃើញថា អង្គជំនុំជម្រះអាចបដិសេធដីកាសម្រេចដែលធ្វើឡើងតាមឆន្ទានុសិទ្ធិរបស់ ស.ច.ស ទាំងពីរ ដែលថា (១) ផ្អែកលើការបកប្រសាយច្បាប់ជាមូលដ្ឋានមិនបានត្រឹមត្រូវ (កំហុសអង្គច្បាប់) ដែលនាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវច្បាស់ក្រឡែត (កំហុសអង្គហេតុ) ដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ និង/ឬ (៣) មានភាពអយុត្តិធម៌ ឬ មិនសមហេតុសមផល ដែលជាការបំពានលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងបង្ខំឱ្យធ្វើការសន្និដ្ឋាន ដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានប្រយ័ត្នប្រយែង[20]។ ជារួម អ.ប.ជ យល់ឃើញថា "ត្រូវបង្ហាញឱ្យឃើញថា សហចៅក្រមស៊ើបអង្កេត មានកំហុស ឬ មានការបំពារបំពាន ដែលមានអានុភាពទៅលើការ

---

[18] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/16 និងឯកសារ D382/19 ទំព័រ ៥-៦។

[19] ដូចយោងខាងលើ កថាខណ្ឌ ១២។

[20] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២១។

អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន"[21]។

១៩. ស្របតាមយុត្តិសាស្ត្រអន្តរជាតិ អ.ប.ជ យល់ឃើញថា "ការភ័ន្តច្រឡំអង្គច្បាប់ដែលបានលើកឡើងត្រូវបានពិនិត្យមើល *ជាថ្មី* ដើម្បីសម្រេចថាតើសេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬទេ"[22]។

## មូលដ្ឋានបណ្តឹងឧទ្ធរណ៍ ÷ សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ ដោយសារការចេញដីកាដំណោះស្រាយចំនួនពីរ

២០. ស.ច.ស ទាំងពីរបានពិនិត្យភ័ស្តុតាងនៅក្នុងសំណុំរឿងដូចគ្នា ប៉ុន្តែ បែរជាបានដាក់ដីកាដំណោះស្រាយផ្ទុយគ្នា និងដោយឡែកពីគ្នាចំនួនពីរទៅវិញ។ ការធ្វើដូច្នេះបានន័យថា ស.ច.ស ទាំងពីរមានកំហុសអង្គច្បាប់ទៅហើយ។ មេធាវីការពារក្តីសន្និដ្ឋានថា (i) ដីកាដំណោះស្រាយទាំងពីរមិនអាចទទួលយកបាន អនុលោមតាមច្បាប់ អ.វ.ត.ក ទេ (ii) ដីកាដំណោះស្រាយផ្ទុយគ្នាចំនួនពីរនេះរំលោភលើគោលការណ៍វិមតិសង្ស័យដែលត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ និងសិទ្ធិរបស់លោក **យឹម ទិត្យ** ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយ អ.ប.ជ ត្រូវបដិសេធដីកាដំណោះស្រាយទាំងពីរ និងលើកលែងការចោទប្រកាន់លើរឿងក្តីនេះ។

## I. ដីកាដំណោះស្រាយទាំងពីរមិនអាចទទួលយកបានអនុលោមតាមច្បាប់ អ.វ.ត.ក

២១. ក្របខណ្ឌច្បាប់ អ.វ.ត.ក ពុំអនុញ្ញាតឲ្យ ស.ច.ស ទាំងពីរ ចេញដីកាដំណោះស្រាយចំនួនពីរដែលផ្ទុយគ្នា និងដោយឡែកពីគ្នានោះទេ។ ស.ច.ស មានកំហុស នៅពេលបានធ្វើដូច្នេះ។

២២. មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា ចែងថា "សហចៅក្រមស៊ើបអង្កេតត្រូវសហការ ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត។ កិច្ចព្រមព្រៀង អ.ស.ប-រាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមជាសន្ធិសញ្ញាទ្វេភាគីត្រូវបកតែបកស្រាយ "ដោយសុទ្ធចិត្តស្របតាមអត្ថន័យដើម ដែលបានកំណត់លើពាក្យពេចន៍នៃ [កិច្ចព្រមព្រៀង] នៅក្នុងបរិបទរបស់វា

---

[21] ដូចយោងខាងលើ កថាខណ្ឌ ២០-២២។ បទដ្ឋានទាំងនេះអនុវត្តចំពោះការធ្វើសេចក្តីសម្រេចទាំងអស់តាមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើអង្កេត។

[22] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១៣។

និងស្របតាមកម្មវត្ថុ និងគោលបំណង"[23]។

២៣. មាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក ចែងកំណត់ថា ការស៊ើបអង្កេតគឺជា "ការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមស៊ើបអង្កេតទាំងពីរ"។ បទប្បញ្ញត្តិនេះចែងថា "រួមគ្នា" ពុំមែន "ក្នុងពេលដំណាលគ្នា" នោះទេ។ ពាក្យពេចន៍នៃបទប្បញ្ញត្តិនេះចែងច្បាស់ និងត្រូវគោរពតាម។

២៤. ការចេញដីកាដំណោះស្រាយមួយ ដើម្បីបិទកិច្ចស៊ើបសួរ ស្ថិតក្រោមវិធាន ៦៧(១) នៃ វិធានផ្ទៃក្នុង ដែលចែងថា "សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់"។ វិធាន ៦៧ ចែងយ៉ាងច្បាស់ថា មានតែដីកាដំណោះស្រាយរួមគ្នាតែមួយចេញដោយ ស.ចៅ.ស ទាំងពីរ ពាក់ព័ន្ធនឹងរឿងក្ដីនីមួយៗប៉ុណ្ណោះ ត្រូវបានអនុញ្ញាត។ ពាក្យពេចន៍នេះជាការដាក់កាតព្វកិច្ច និងអនុញ្ញាតឱ្យចោទប្រកាន់បញ្ជូនជនជាប់ចោទទៅជំនុំជម្រះ (ចំពោះបទចោទទាំងអស់ ឬ បទចោទខ្លះ) ឬ លើកលែងការចោទប្រកាន់ចំពោះជនជាប់ចោទទាំងស្រុងតែម្ដង។

២៥. វិធាន ១៤ ប្រមើលមើលថា ស.ចៅ.ស ទាំងពីរ នឹងបំពេញកិច្ចស៊ើបសួររបស់ខ្លួនរួមគ្នា ហើយមានសិទ្ធិអំណាចស្មើគ្នា និងពុំបានចែងពីករណីដែល ស.ចៅ.ស ទាំងពីរបំពេញកិច្ចដោយឡែកពីគ្នាក្នុងការចេញដីកាដំណោះស្រាយនោះទេ។

២៦. យើងពុំឃើញមានចែងនៅត្រង់ផ្នែកណាមួយនៃកិច្ចព្រមព្រៀង អ.ស.ប និងរាជរដ្ឋាភិបាល ច្បាប់ អ.វ.ត.ក ឬ វិធានផ្ទៃក្នុង អំពីលទ្ធភាពដែល ស.ចៅ.ស ទាំងពីរ បំពេញកិច្ចដោយឯកតោភាគីក្នុងការចេញដីកាដំណោះស្រាយដោយឡែកពីគ្នាមួយ ពាក់ព័ន្ធនឹងជនត្រូវចោទនោះទេ។ កិច្ចបែបនោះពុំត្រូវបានប្រមើលមើលទុកជាមុនជាក់លាក់នោះទេ។

២៧. ស្ថានភាពតែមួយគត់ ដែលកិច្ចរួមគ្នាដោយ ស.ចៅ.ស ទាំងពីរ អាចធ្វើទៅបាន គឺនៅក្នុងករណីដែលចៅក្រមទាំងពីរបានប្រើប្រាស់អំណាចមានកម្រិតរបស់ខ្លួន ក្នុងការធ្វើប្រតិភូកម្មកិច្ចការតុលាការអនុលោមតាមវិធាន ១៤(៤)។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រតិភូកម្មនេះពុំអនុវត្តចំពោះកិច្ចដែលត្រូវបានធ្វើឡើងរួមគ្នា អនុលោមតាមច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងនោះទេ។ នៅក្នុងស្ថានភាព

---

[23] អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា លេខ 1155 UNTS 331 ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ មាត្រា ៣១(១)។ កិច្ចព្រមព្រៀងរបស់ អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២(២)។

ពិសេស ដែល ស.ច.ស ទាំងពីរ ពុំតម្រូវឲ្យបំពេញកិច្ចរួមគ្នា ស.ច.ស ម្នាក់ៗ អាចបំពេញកិច្ចជាលក្ខណៈបុគ្គល *តែ* ក្នុងករណីដែលពួកគាត់បានធ្វើប្រតិភូកម្មអំណាចឲ្យបំពេញកិច្ចបែបនោះ ទៅឲ្យចៅក្រមណាម្នាក់ "តាមរយៈលិខិតរួមគ្នាជាលាយលក្ខណ៍អក្សរ"[24]។

២៨. បទប្បញ្ញត្តិនៃមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២២*ថ្មី* នៃច្បាប់ អ.វ.ត.ក វិធាន ៦៧ និងការគ្មានបទប្បញ្ញត្តិចែងអំពីលទ្ធភាពនៃដីកាដំណោះស្រាយពីរ មានន័យថា ការចេញដីកាដំណោះស្រាយគឺជាកិច្ចដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃវិធាន ១៤(៤) ពោលគឺកិច្ចនេះ *ត្រូវ* "ឲ្យអនុវត្តដោយរួមគ្នា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងវិធានផ្ទៃក្នុងនេះ"។ គ្មានការធ្វើប្រតិភូកម្មណាមួយអាចធ្វើទៅបាន (ហើយ ទោះក្នុងករណីណាក៏ដោយ ពុំមាន ស.ច.ស ណាម្នាក់បានធ្វើប្រតិភូកម្មទៅកាន់ចៅក្រមម្នាក់ទៀត នូវអំណាចក្នុងការចេញដីកាដំណោះស្រាយនោះទេ)។ ស.ច.ស ទាំងពីរពុំត្រូវបានអនុញ្ញាតឲ្យបំពេញកិច្ចជាលក្ខណៈបុគ្គល ឬ ចេញដីកាបង្គាប់ណាមួយក្រៅពីដីកាដំណោះស្រាយរួមគ្នានោះឡើយ។

២៩. យ៉ាងហោចណាស់ ដោយសារការគ្មាននីត្យានុកូលភាពយ៉ាងច្បាស់ក្រឡែតនៃដីកាដំណោះស្រាយទាំងពីរនេះ ស.ច.ស គួរប្រើប្រាស់ឥស្សរចិត្ត និងស្នើសុំបញ្ជាក់បំភ្លឺលើបញ្ហានេះ ពី អ.ប.ជ នៅមុនពេលចេញដីកាដំណោះស្រាយដោយឡែកពីគ្នារបស់ខ្លួន។ ការធ្វើបែបនេះអាចដោះស្រាយភាពស្រពិចស្រពិល និងធានាបាននូវភាពឆាប់រហ័សផ្នែកនីតិវិធី។

៣០. ដោយពិចារណាលើមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២៣*ថ្មី* នៃច្បាប់ អ.វ.ត.ក វិធាន ១៤ (រួមទាំង ភាពមិនអាចអនុវត្តបាននៃអញ្ញត្រកម្មនៅក្នុងវិធាន ១៤(៤)) វិធាន ៦៧ និងការគ្មានបទប្បញ្ញត្តិចែងអំពីលទ្ធភាពនៃដីកាដំណោះស្រាយទាំងពីរ កិច្ចរបស់ ស.ច.ស មិនត្រូវបានអនុញ្ញាតនោះទេ។

---

[24] វិធាន ១៤(៤) នៃវិធានផ្ទៃក្នុងចែងថា៖ "វៀរលែងតែសកម្មភាពណា ដែលតម្រូវឲ្យអនុវត្តដោយរួមគ្នា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតអាចផ្ទេរភារកិច្ចទៅឲ្យសហចៅក្រមស៊ើបអង្កេតណាមួយក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីរ តាមរយៈលិខិតរួមគ្នាជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យបំពេញកិច្ចតែម្នាក់ឯងបាន។

## II. ដីកាដំណោះស្រាយផ្ទុយគ្នាទាំងពីរនេះបានបំពានគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក យឹម ទិត្យ

៣១. ដីកាដំណោះស្រាយដោយឡែកពីគ្នារបស់ ស.ច.ស បានវាយតម្លៃលើភស្តុតាងអង្គហេតុតែមួយ ប៉ុន្តែបែរជាធ្វើសេចក្តីសន្និដ្ឋានផ្ទុយគ្នាទៅវិញ លើចំណុចថាតើលោក **យឹម ទិត្យ** ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការដែរឬទេនោះ។ ដោយពិចារណាលើសមភាពរវាងចៅក្រម និងការទទួលខុសត្រូវរួមក្នុងការបំពេញរួមគ្នា ស.ច.ស ទាំងពីរត្រូវអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ចំពោះការវាយតម្លៃរបស់ខ្លួនលើអង្គហេតុ ហើយត្រូវលើកលែងការចោទប្រកាន់ប្រឆាំងនឹងលោក **យឹម ទិត្យ**។ ផ្ទុយទៅវិញ ស.ច.ស បានធ្វើឱ្យប៉ះពាល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ លោក **យឹម ទិត្យ** ដោយបានចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា។

៣២. ស.ច.ស ទាំងពីរ គឺជាអ្នកទទួលភារៈលើកិច្ចស៊ើបសួរ ហើយមាន "កាតព្វកិច្ចជាសារវន្តត្រូវរក្សាសុចរិតភាព...នៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០៤"[25]។ ពីមុន នៅពេល ស.ច.ស ទាំងពីរជឿជាក់ថា កិច្ចដំណើរការនីតិវិធីមានហានិភ័យក្នុងការក្លាយជា "មិនស្របតាមគោលការណ៍គ្រឹះនៃការជំនុំជម្រះក្តីដោយយុត្តិធម៌ នីតិរដ្ឋ និងឯករាជ្យភាពតុលាការ" ចៅក្រមបានទទួលស្គាល់ "តាមពាក្យសច្ចាប្រណិធានរបស់យើងពេលចូលកាន់តំណែង យើងមានភារកិច្ចត្រូវពិចារណាលើជម្រើសទាំងអស់ និងជម្រើសណាក៏ដោយ ដើម្បីធានាថា ការវិវត្តទៅមុខនៅក្នុងកិច្ចស៊ើបសួរនៅចំពោះមុខតុលាការត្រូវគោរពគោលការណ៍គ្រឹះទាំងនេះ"[26]។ ស.ច.ស ទាំងពីរបានផ្តល់ការសង្កេតថា "វាច្បាស់ជាបញ្ហាអង្គច្បាប់នៅក្នុងចំណោម "ប្រទេសស៊ីវិល័យ" តាមអត្ថន័យនៃមាត្រា ៣៨(១)(ឃ) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ដោយសារតឡូវនេះ ចៅក្រមក៏ត្រូវតែធានា

---

[25] ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ឯកសារ D229/3 កថាខណ្ឌ ២៦។

[26] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D355 កថាខណ្ឌ ១។

ឲ្យមានការគោរពតាមវិធានការការពារនីតិវិធីនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌផងដែរ”[27]។

៣៣. គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាសមាសធាតុស្នូលនៃសច្ចធារណ៍និរទោស ដែលត្រូវបានធានានៅក្រោមរដ្ឋធម្មនុញ្ញកម្ពុជា[28] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[29] ច្បាប់ អ.វ.ត.ក[30] និងច្បាប់អន្តរជាតិ[31]។ គោលការណ៍នេះកំណត់ថា វិមតិសង្ស័យត្រូវបកស្រាយជាប្រយោជន៍ដល់ជនជាប់ចោទ និងអនុវត្តចំពោះភាពស្រពិចស្រពិល នៅពេលសម្រេចលើអង្គហេតុផ្នែកភស្តុតាង និងការសម្រេចលើការទទួលខុសត្រូវបុគ្គល[32]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា គោលការណ៍នេះ “មានមុខងារជាចំបងក្នុងការបង្ហាញឲ្យឃើញនូវការយល់ដឹងជា

[27] ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D355/9 កថាខណ្ឌ ១៧។

[28] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨។ រាល់ករណីសង្ស័យត្រូវតែដោះស្រាយដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទ។

[29] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៥១។

[30] សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១, ៣០១៤។ សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ២២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

[31] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(២)។ តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គបុរេជំនុំជម្រះ II រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Bemba* “សេចក្តីសម្រេច អនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីការ ចោទប្រកាន់របស់រដ្ឋអាជ្ញាប្រឆាំងនឹង Jean-Pierre Bemba Gombo” ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ លេខ ICC-01/05-01/08-424 កថាខណ្ឌ ៣១។

[32] សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១, ៣០១៤៖ អង្គជំនុំជម្រះបានដោះស្រាយលើបញ្ហាស្រពិចស្រពិលអង្គហេតុ ដោយ “អនុវត្តការបកស្រាយដែលជាប្រយោជន៍បំផុតដល់ជនជាប់ចោទ ស្របតាមគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ”។ សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ២២៖ “បន្ទាប់ពីបានវាយតម្លៃទៅលើភស្តុតាងដោយមានសំអាងហេតុរួច អង្គជំនុំជម្រះនឹងធ្វើការបកស្រាយវិមតិសង្ស័យដោយផ្តល់ផលប្រយោជន៍ដល់ជនជាប់ចោទ”។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

ស្វ័យប្រវត្តិ ក្នុងករណីដែលពុំមានភស្តុតាងលុបបំបាត់ភាពមន្ទិលសង្ស័យ"[33]។ គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* អនុវត្តនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី រួមទាំង ដំណាក់កាលមុនអង្គសេចក្តីផងដែរ[34]។

៣៤. រឿងក្តីរបស់ លោក **យឹម ទិត្យ** ធ្លាប់ជា និងនៅតែជា ឧទាហរណ៍នៃស្ថានភាពវិមតិសង្ស័យដែលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ)។ ចៅក្រមពីរដែលមានសិទ្ធិស្មើគ្នា មានភារកិច្ចបំពេញកិច្ចរួមគ្នា បានធ្វើការវាយតម្លៃលើអង្គហេតុភស្តុតាងតែមួយនៅក្នុងសំណុំរឿង និងបានឈានដល់ការសន្និដ្ឋានផ្ទុយគ្នាអំពីករណីថាតើលោក **យឹម ទិត្យ** គួរបញ្ជូនទៅជំនុំជម្រះឬអត់នោះ។ ស.ច.ស.ជ បានសន្និដ្ឋានថា លោក **យឹម ទិត្យ** ពុំស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការនោះទេ ហើយបានលើកលែងការចោទប្រកាន់[35] ខណៈ ស.ច.ស.អ បានសន្និដ្ឋានដោយផ្អែកលើភស្តុតាងដូចគ្នាថា លោក **យឹម ទិត្យ** ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការ ដោយបានចោទប្រកាន់បញ្ជូនគាត់ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មទាំងនេះ[36]។ ជាសំខាន់ អត្ថិភាពនៃដីកាដំណោះស្រាយផ្ទុយគ្នាទាំងពីរនេះនាំឲ្យមានវិមតិសង្ស័យអំពីការសម្រេចលើអង្គហេតុ និងការវាយតម្លៃរួមលើការទទួលខុសត្រូវបុគ្គល ដូចការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយផ្ទុយគ្នានីមួយៗ។ នៅក្នុងតួនាទីជាអ្នកវិនិច្ឆ័យលើអង្គហេតុ

---

[33] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

[34] ឧទាហរណ៍ សូមមើល៖ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៣១០។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ១៤៤។ សូមមើលផងដែរ៖ តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គបុរេជំនុំជម្រះ II រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Bemba* "សេចក្តីសម្រេច អនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីការចោទប្រកាន់របស់រដ្ឋអាជ្ញាប្រឆាំងនឹង Jean-Pierre Bemba Gombo" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ លេខ ICC-01/05-01/08-424 កថាខណ្ឌ ៣១៖ "ចុងក្រោយក្នុងការសម្រេចបែបនេះ [ស្តីពីការបញ្ជាក់នូវបទចោទ] អង្គជំនុំជម្រះចង់ធ្វើការគូសបញ្ជាក់ថា មានការណែនាំពីគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ ជាសមាសធាតុមួយនៃការសន្មតជាមុនថាគ្មានទោស ដែលជាគោលការណ៍ទូទៅនៅក្នុងនីតិវិធីព្រហ្មទណ្ឌអនុវត្តដូចគ្នានៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី រួមទាំងដំណាក់កាលមុនជំនុំជម្រះផងដែរ"។

[35] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ កថាខណ្ឌ ៦៦៦-៦៨៧។

[36] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៩៩២-៩៩៨។

ស.ច.ស មានកាតព្វកិច្ចអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវគោលការណ៍ *វិមតិសង្ស័យបានទៅជាប្រយោជន៍ដល់ជនជាប់ចោទ*។ ពុំមានការអនុញ្ញាតឲ្យ ស.ច.ស ទាំងពីរចេញដីកាដំណោះស្រាយផ្ទុយគ្នានោះទេ តែផ្ទុយទៅវិញ ស.ច.ស ទាំងពីរលើកលែងការចោទប្រកាន់តាមផ្លូវតុលាការ។ សច្ចធារណ៍និរទោស គឺជាវិធាននៃច្បាប់ព្រហ្មទណ្ឌ។ វាមានឧត្តមភាពលើករណីនៃវិមតិសង្ស័យទាំងអស់។ វាត្រូវមានឧត្តមភាពនៅក្នុងករណីនេះ។

៣៥. ម្យ៉ាងវិញទៀត ស.ច.ស ទាំងពីរបានបង្កើតភាពពុំច្បាស់លាស់ផ្នែកនីតិវិធី ហើយធ្វើឲ្យកាន់តែមានវិមតិសង្ស័យ។ គោលបំណងនៃដីកាដំណោះស្រាយគឺដើម្បីបញ្ជាក់បំភ្លឺផ្លូវច្បាប់នៅពេលបិទបញ្ចប់កិច្ចស៊ើបសួរ[37]។ ដូច ស.ច.ស.អ បានទទួលស្គាល់ ការចេញដីកាដំណោះស្រាយផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា បង្កើតនូវ "*ភាពមិនច្បាស់លាស់ផ្នែកនីតិវិធី*"[38] ហើយ ជាសំខាន់ ស.ច.ស.អ បានទទួលស្គាល់ថាបានបំពានសិទ្ធិរបស់ លោក **យឹម ទិត្យ** ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់[39] ធ្វើឲ្យលោកស្ថិតនៅក្នុងស្ថានភាពមួយមិនអាចទទួលយកបាន ពោលគឺ ធ្វើឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅមិនមានសេចក្ដីសម្រេចជាក់លាក់លើរូបលោក។ នេះជាស្ថានភាពមួយដែលត្រូវបានទទួលស្គាល់ដោយ ស.ច.ស.អ ថា "*វាជាការមិនស្របតាមតម្រូវការជាមូលដ្ឋាននៃនីតិរដ្ឋ*"[40]។ ដោយសារ ស.ច.ស ទាំងពីរបានដឹងថា ការចេញដីកាដំណោះស្រាយពីរនឹងបង្កឲ្យមានការភាន់ច្រឡំផ្នែកនីតិវិធី ស.ច.ស ទាំងពីរត្រូវធ្វើយ៉ាងណាព្យាយាមសុំការបំភ្លឺពី អ.ប.ជ មុនពេលពិចារណាបំពេញកិច្ចដែលមិនសមស្រប និងដោយធ្វេសប្រហែសបែបនេះ[41]។ ស.ច.ស ទាំងពីរ មិនបានស្នើសុំការបំភ្លឺបែបនេះនោះទេ តែបែរជាទម្លាក់បន្ទុកលើ លោក **យឹម ទិត្យ** ដោយសារមិនមានការបញ្ជាក់ផ្នែកនីតិវិធីឲ្យបានជាក់លាក់។ ករណីទាំងអស់នេះបានកើតឡើង បើទោះជាមានការពន្យារកិច្ចដំណើរការនីតិវិធីមិនអាចទទួលយកបាន ចំពោះ លោក **យឹម ទិត្យ** អស់រយៈពេលជាង ១៣ ឆ្នាំរួចហើយក៏ដោយ

[37] វិធាន ៦៧ នៃវិធានផ្ទៃក្នុង។

[38] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០៤២។

[39] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(១)។ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥*ថ្មី*(ក)។ វិធាន ២១(១) នៃវិធានផ្ទៃក្នុង។

[40] សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D355 កថាខណ្ឌ ៥៤។

[41] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០៤២។

ក្តី[42]។ កិច្ចខុសច្បាប់ និងគ្មានការទទួលខុសត្រូវរបស់ ស.ច.ស ទាំងពីរ បានធ្វើឲ្យកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ មានភាពស្មុគស្មាញប្រទាក់ក្រឡាគ្នា ដែលជាការកាន់តែរាំងដល់ការបញ្ចប់រឿងក្តី ០០៤ ក្នុងរយៈពេលសមហេតុផលបន្ថែមទៀត[43]។

៣៦. សរុបមកវិញ នៅពេលចេញដីកាដំណោះស្រាយពីរដែលច្បាប់មិនអនុញ្ញាត ហើយខកខានក្នុងការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ស.ច.ស ទាំងពីរខកខានក្នុងការបំពេញតួនាទីចម្បងរបស់ខ្លួនក្នុងការធ្វើជាអ្នកធានាមើលការខុសត្រូវលើការស៊ើបអង្កេត ហើយ បែរជា បំពានយ៉ាងសកម្មលើសិទ្ធិទទួលបានការជំនុំជម្រះរបស់លោក **យឹម ទិត្យ** ទៅវិញ។

## III. អ.ប.ជ ត្រូវបដិសេធដីកាដំណោះស្រាយទាំងពីរ និងលើកលែងការចោទប្រកាន់លើរឿងក្តីនេះ

៣៧. អ.ប.ជ មានការទទួលខុសត្រូវសំខាន់ក្នុងការធានាបាននូវភាពយុត្តិធម៌ក្នុងកិច្ចដំណើរការនីតិវិធី[44]។ ជាអកុសល ស.ច.ស ទាំងពីរខកខានក្នុងការបំពេញភារកិច្ចតាមផ្លូវតុលាការគោរពច្បាប់ និងការពារសិទ្ធិជំនុំជម្រះដោយយុត្តិធម៌របស់ លោក **យឹម ទិត្យ**។ ទោះបីជា ស.ច.ស ទាំងពីរ គួរតែស្នើសុំការណែនាំពី អ.ប.ជ មុនពេលចេញដីកាដំណោះស្រាយទាំងពីរ ជាការសោកស្តាយ ស.ច.ស ទាំងពីរពុំបានធ្វើដូច្នេះទេ។ ការទទួលខុសត្រូវនាពេលនេះគឺអាស្រ័យលើ អ.ប.ជ ជាអ្នកសម្រេចឲ្យបានចប់ចុងចប់ដើម ក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធីនៅដំណាក់កាលនេះ និងការពារសិទ្ធិមូលដ្ឋានរបស់ លោក **យឹម ទិត្យ** ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

៣៨. ក្របខណ្ឌច្បាប់នៅ អ.វ.ត.ក ចែងប្រមើលមើល និងអនុញ្ញាតឲ្យចេញដីកាដំណោះស្រាយរួមតែមួយដើម្បីបញ្ចប់កិច្ចស៊ើបសួរលើជនត្រូវចោទណាម្នាក់ ដែលអាចចេញដោយ ស.ច.ស ទាំងពីររួមគ្នា

---

[42] សូមមើល បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤០-៤៥។

[43] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(ក)។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥*ថ្មី*(គ)។

[44] សំណុំរឿង ០០៤/២ សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ D360/3 កថាខណ្ឌ ៦៖ អ.ប.ជ យល់ឃើញថា "វាមានលក្ខណៈសមស្របក្នុងការអនុវត្តយុត្តាធិការដែលខ្លួនទទួលបាន ក្នុងនាមជាអង្គជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍ នៅដំណាក់កាលមុនអង្គសេចក្តី និងនៅពេលពុំមានសេចក្តីសម្រេចជាក់លាក់ណាមួយ [...] ដើម្បីផលប្រយោជន៍នៃយុត្តិធម៌"។

លើកលែងតែក្នុងករណី ស.ច.ស បានផ្ទេរប្រតិភូអំណាចនេះឱ្យទៅ ស.ច.ស ម្នាក់ទៀត ប៉ុន្តែ ករណីបច្ចុប្បន្ន មិនបានធ្វើដូចនេះនោះទេ។ ជាលទ្ធផល ពុំមានដីកាដំណោះស្រាយណាមួយ មានសុពលភាពនោះឡើយ ពោលគឺ ដីកាដំណោះស្រាយទាំងពីរត្រូវចាត់ទុកជាមោឃៈ ដោយសារវាមានវិការៈផ្នែកនីតិវិធី អនុលោមតាមវិធាន ៦៧(២)។ ដោយសារពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនោះ ហេតុដូច្នេះ វិធាន ៧៧(១៣)(ខ) ពុំអាចយកមកអនុវត្តបាននោះឡើយ។ ប្រសិនបើ អ.ប.ជ មិនអាចចេញសេចក្តីសម្រេចតាមសម្លេងភាគច្រើនលើសលប់នោះទេ អង្គជំនុំជម្រះសាលាដំបូងមិនអាចទទួលសំណុំរឿងនេះមកជំនុំជម្រះផ្អែកលើដីកាដំណោះស្រាយដែលគ្មានសុពលភាពចេញដោយ ស.ច.ស តែម្នាក់នោះទេ[45]។

៣៩. អ.ប.ជ យល់ឃើញថា "ខ្លួនបានបំពេញតួនាទីជាសភាស៊ើបសួរតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជានៅក្នុង អ.វ.ត.ក" ហើយនៅពេលបានទទួលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ "នៅក្នុងវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ស្នើឡើងថា អង្គបុរេជំនុំជម្រះមានអំណាចចេញដីកាដំណោះស្រាយថ្មីមួយ ឬ ចេញដីកាដំណោះស្រាយដែលបានកែប្រែរួច។ ដីកានេះនឹងយកមកធ្វើជាមូលដ្ឋាននៃការជំនុំជម្រះ"[46]។ មេធាវីការពារក្តីសន្និដ្ឋានថា នីតិវិធីជាធរមាន ដែល អ.ប.ជ អាចអនុវត្តបាននាពេលនេះ គឺ (i) បដិសេធដីកាដំណោះស្រាយដែលមានវិការៈទាំងស្រុងតែម្តង[47] (ii) បដិសេធដីកាដំណោះស្រាយដែលមានវិការៈ និងបង្វិលសំណុំរឿងទៅ ស.ច.ស ដោយបង្គាប់ឱ្យចេញដីកាដំណោះស្រាយរួមគ្នាស្របតាមច្បាប់ជាធរមាន ដោយកត់សម្គាល់ថា ការខ្វែងយោបល់គ្នាជាបន្តត្រូវសម្រេចដោយផ្តល់ប្រយោជន៍ដល់លោក **យឹម ទិត្យ**[48] ឬ បដិសេធ

[45] វិធាន ៧៩ នៃវិធានផ្ទៃក្នុង៖ "អង្គជំនុំជម្រះសាលាដំបូងទទួលបណ្តឹងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ"។

[46] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារD99/3/42 កថាខណ្ឌ ៤០។ សូមមើលផងដែរ៖ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២២។

[47] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥*ថ្មី*។ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(២)។

[48] វិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៥១។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥*ថ្មី*។ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(២)។ សូមមើលផងដែរ៖ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍

ដីកាដំណោះស្រាយ វាយតម្លៃសំណុំរឿង ០០៤ និងចេញដីកាដំណោះស្រាយមួយដោយឡែក សម្រេចចោទប្រកាន់ លោក **យឹម ទិត្យ** ឬ លើកលែងការចោទប្រកាន់លើរឿងក្តី[49]។

៤០. មេធាវីការពារក្តីសន្និដ្ឋានថា អ.ប.ជ *ពុំមាន* លទ្ធភាពបដិសេធដីកាដំណោះស្រាយណាមួយ ជាដាច់ខាត។ ស.ច.ស ទាំងពីរ ជាចៅក្រមមានឋានៈស្មើគ្នា ហើយយោងតាមអញ្ញត្រកម្មនៃសច្ចធារណ៍និរទេស ច្បាប់ជាធរមានពុំអនុញ្ញាតឱ្យ អ.ប.ជ សម្រេចថា កិច្ចរបស់ ស.ច.ស ណាម្នាក់មានឧត្តមភាពនោះទេ។ ម្យ៉ាងវិញទៀត ការគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានសុពលភាព មានន័យថា អង្គជំនុំជម្រះសាលាដំបូងពុំអាចទទួលសំណុំរឿងនេះយកមកជំនុំជម្រះតាមរយៈលក្ខខណ្ឌ អនុលោមតាមវិធាន ៧៧(១៣)(ខ) នោះទេ។ ករណីដែល ស.ព.ជ ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចលើអង្គសេចក្តីនៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ ខណៈ ស.ព.អ ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការសម្រេចអង្គសេចក្តីនៃដីកាដំណោះស្រាយរបស់ ស.ច.ស.ជ កាន់តែធ្វើឱ្យស្ថានភាពនេះកាន់តែស្រពិចស្រពិលខ្លាំងឡើង[50]។ នៅក្នុងកាលៈទេសៈបច្ចុប្បន្ន សច្ចធារណ៍និរទោស គោលការណ៍ពាក់ព័ន្ធនៃ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* តម្រូវឱ្យលើកលែងចោទប្រកាន់លើសំណុំរឿង ០០៤។

---

របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២២។

[49] វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៥១។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥*ថ្មី*។ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(២)។ សូមមើលផងដែរ៖ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២២។

[50] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាជាតិអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ D382/4។ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (D381) ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/4។

**ឧបាស្រ័យ**

**អាស្រ័យហេតុនេះ** ផ្អែកលើហេតុផលទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមគោរពស្នើឲ្យអង្គបុរេជំនុំជម្រះ ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ និងអនុវត្តឆន្ទានុសិទ្ធិ ៖

(១) **សម្រេច** មិនទទួលយកបណ្តឹងឧទ្ធរណ៍ និង

(២) **បដិសេធ** ដីកាដំណោះស្រាយដែលមានវិការៈទាំងស្រុងតែម្តង ហើយលើកលែងការចោទប្រកាន់ប្រឆាំងនឹងលោក យឹម ទិត្យ ឬ

(៣) **ច្រោលចោល** ដីកាដំណោះស្រាយដែលមានវិការៈ និងបង្វិលសំណុំរឿងទៅ ស.ច.ស ទាំងពីរ ហើយបង្គាប់ឲ្យចេញដីកាដំណោះស្រាយមួយរួមគ្នា ស្របតាមច្បាប់ជាធរមាន ដោយមានការកត់សម្គាល់ថា បើនៅតែមានការខ្វែងយោបល់គ្នា នោះនឹងត្រូវសម្រេចដោយផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ *ឬ*

(៤) **បដិសេធ** ដីកាដំណោះស្រាយដែលមានវិការៈ វាយតម្លៃសំណុំរឿង ០០៤ ដោយផ្ទាល់ និងចេញដីកាដំណោះស្រាយ សម្រេចចោទប្រកាន់លោក **យឹម ទិត្យ** ទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ប្រឆាំងនឹងរូបលោក។

សូម លោកចៅក្រម ទទួលយកបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព។

________________ ____________________

សូ មូស្សេទី Suzana TOMANOVIĆ

សហមេធាវីការពារក្តីលោក យឹម ទិត្យ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩